ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ
សំណុំរឿងព្រហ្មទណ្ឌ
លេខ ១០២
ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២២
**សាលដីកា**
លេខ **១១២ I**
ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣

# សាលដីកា
## តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១.ឯកឧត្តម [redacted] ជាប្រធាន

២.ឯកឧត្តម [redacted] ជាចៅក្រម

៣.ឯកឧត្តម [redacted] ជាចៅក្រម

៤.ឯកឧត្តម [redacted] ជាចៅក្រម

៥.លោកជំទាវ [redacted] ជាចៅក្រម

**ចៅក្រមរបាយការណ៍**

លោកជំទាវ [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

**តំណាងម[redacted]ការ**

ឯកឧត្តម [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ **៤៤៥ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២** របស់ឈ្មោះ [redacted] **សុខោ** ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ **៧៩ក្រ III "ឃ" ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលមាន ៖

**ជនត្រូវចោទ ៖**

-ឈ្មោះ [redacted] **ពេជ្រតារា** ភេទស្រី កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ មុខរបរគ្មាន ទីកន្លែងកំណើតនៅភូមិ [redacted] ខេត្តកំពង់ស្ពឺ មានលំនៅដ្ឋាននៅ [redacted]

ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្តាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

-មានមេធាវីលោកស្រី [redacted] **ស្រីអូន** និងលោក [redacted] **គន្ធា** ជាមេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ។

**ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យពីបទអំពើលួចនិងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

**ដើមបណ្តឹងរដ្ឋប្បវេណី (ជាបុគ្គលម្ចាស់សាធុទ្ធ)** ៖

**ធនាគារ ស្ថាបនា សាខាស្រុកអង្គស្នួល ឃុំដំណាក់អំពិល** មានអាសយដ្ឋានចុះបញ្ជីពាណិជ្ជកម្មស្ថិតនៅផ្លូវជាតិលេខ៤ ភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានលោក [redacted] **ចាន់វីរៈ** ជានាយកសាខាស្តីទី និងជាតំណាងឱ្យធនាគារ។

## អំពីអង្គហេតុ

កាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០២០ មានជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានចូលបម្រើការងារជាមន្ត្រីចុះកិច្ចសន្យានៅធនាគារ ស្ថាបនា សាខាអង្គស្នួល ឃុំដំណាក់អំពិល ស្ថិតក្នុងភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល ដែលមានតួនាទីជាបេឡាករ (Teller)។ ចាប់តាំងពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ ជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា បានលួចដកប្រាក់របស់អតិថិជននិងក្លែងបន្លំស្នាមមេដៃរបស់អតិថិជនជាបន្តបន្ទាប់សរុបចំនួន ២៨ប្រតិបត្តិការ សរុបជាប្រាក់មានចំនួន ៣.០៧៨,២៥ (បីពាន់ចិតសិបប្រាំបីដុល្លារក្បៀសម្ភៃប្រាំសេន) ដុល្លារអាមេរិក។ នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ជនត្រូវចោទឈ្មោះ ឡៃ ពេជ្រតារា បានលួចដកប្រាក់ពីគណនីរបស់ឈ្មោះ សុខផ្ញើម វិសុទ្ធ ចំនួន៥០០ (ប្រាំរយ) ដុល្លារអាមេរិក ដោយប្រើវិធីក្លែងបន្លំស្នាមមេដៃរបស់អតិថិជនដដែល ក្រោយមកធនាគារក៏ចាប់បានទើបធ្វើកិច្ចសន្យាបញ្ឈប់ជននេះពីការងារ និងដាក់ពាក្យបណ្តឹងមកកាន់សាលាដំបូងខេត្តកណ្តាលតែម្តង។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ **៥២៧ ដកសព/២២ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២២** របស់អយ្យការអមសាលាដំបូងខេត្តកណ្តាលដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

ប្តឹងសុំចៅក្រមស៊ើបសួរសម្រេច៖

-លើកលែងការចោទប្រកាន់លើជនត្រូវចោទ៖

ឈ្មោះ [redacted] **ពេជ្រតារា** ភេទស្រី អាយុ៣២ឆ្នាំ ពីបទអំពើលួចនិងក្លែងបន្លំ ប្រព្រឹត្តនៅភូមិ ថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្តាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣

ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និង មាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា ភេទស្រី អាយុ៣២ឆ្នាំ ជនជាតិខ្មែរ មុខរបរនៅផ្ទះ [redacted] ខេត្តកំពង់ស្ពឺ មានលំនៅដ្ឋាននៅ [redacted] ខេត្តកំពង់ស្ពឺ ឪពុកឈ្មោះ [redacted] (រ) ម្ដាយឈ្មោះ [redacted] (រ) នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ពីបទ៖ **អំពើលួច និងក្លែងបន្លំ** ប្រព្រឹត្តនៅភូមិថ្នល់ទទឹង ឃុំដំណាក់អំពិល ស្រុកអង្គស្នួល ខេត្តកណ្ដាល កាលពីថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២២ តាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៦, មាត្រា ៦២៦ និងមាត្រា៦២៧ នៃក្រមព្រហ្មទណ្ឌ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ **០៣៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២** របស់លោក [redacted] **សុខា** ជាមេធាវីតំណាងឲ្យ **ធនាគារ ស្ថាបនាភីអិលស៊ី** មិនសុខចិត្តនឹងដីកាដំណោះស្រាយលេខ **១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងខេត្តកណ្ដាល លើចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ០៣៥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] ចាន់វីរៈ ជានាយកស្ដីទី និងជាតំណាងឲ្យធនាគារ មិនសុខចិត្តនឹងដីកាដំណោះស្រាយលេខ **១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២** របស់សាលាដំបូងខេត្តកណ្ដាល លើចំនុចនៃសេចក្ដីសម្រេចទាំងមូល ។

-បានឃើញ សាលដីកាលេខ **៧៩ ក្រIII "ឃ" ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ ៖

១-ទទួលបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២២ របស់លោក [redacted] សុខា ជាមេធាវីតំណាងឱ្យធនាគារ ស្ថាបនា ភីអិលស៊ី និងបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២២ លោក ទេព ចាន់វីរៈ ជាតំណាងឱ្យធនាគារ ស្ថាបនា ភីអិលស៊ី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធ ចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ សម្រេចរបស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្ដាលទុកជាបានការដដែល។

៣-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃសុក្រ ៥កើត ខែអស្សុជ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦ ត្រូវនឹងថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៤៤៥ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២ របស់ឈ្មោះ [redacted] សុខោ ជាមេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រង់ចំណុចនៃសេចក្ដីសម្រេចទាំងមូល ។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានធ្វើសេចក្ដីរាយការណ៍។

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្ដីសន្និដ្ឋាននិងប្ដឹងសុំថា ៖ សាលដីកាព្រហ្មទណ្ឌលេខ ៧៩ ក្រ III "ឃ" ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញដែលបានតម្កល់ដីកាដំណោះស្រាយលេខ ១០១៦ ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាដំបូងខេត្តកណ្ដាល ជាសេចក្ដីសម្រេចមានសំអាងហេតុត្រឹមត្រូវហើយ។

**-យល់ឃើញថា** បណ្ដឹងសាទុក្ខពុំមានមូលហេតុតាមបញ្ញត្តិមាត្រា ៤១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ គប្បីក្រុមប្រឹក្សាពិចារណាសម្រេចតាមច្បាប់។

**<u>ហេតុដូច្នេះ</u>**

**<u>តំណាងមហាអយ្យការប្ដឹងសុំក្រុមប្រឹក្សាសម្រេច</u>**

១-ទទួលបណ្ដឹងសាទុក្ខលេខ ៤៤៥ ថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ របស់លោក [redacted] សុខោ ជាមេធាវីការពារសិទ្ធិឱ្យដើមបណ្ដឹងរដ្ឋប្បវេណីទុកជាត្រឹមត្រូវតាមទម្រង់ តែផ្ទុយនិងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៧៩ ក្រ III "ឃ" ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២ របស់សាលាឧទ្ធរណ៍ភ្នំពេញទុកជាបានការដដែល។

+ក្រឡាបញ្ជីអានសារណាការពាររបស់មេធាវី [redacted] **សុខោ** ជាមេធាវីក្រុមហ៊ុនីហ្គលថៅន តំណាងឱ្យធនាគារស្ថាបនា ភីអិលស៊ី ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០២២ ។

+ជនជាប់ចោទឈ្មោះ [redacted] **ពេជ្រតារា** ឆ្លើយថាខ្លួនកើតថ្ងៃទី១ ខែមករា ឆ្នាំ១៩៩១ ខ្លួនសូមឱ្យតុលាការតម្កល់សាលដីការបស់សាលាឧទ្ធរណ៍នៅដដែល ។

+លោកមេធាវី [redacted] **គន្លា** ការពារជនជាប់ចោទឈ្មោះ [redacted] **ពេជ្រតារា** ធ្វើសេចក្ដីសន្និដ្ឋានថា ក្នុងរឿងនេះខាងធនាគារស្ថាបនាបានប្ដឹងកូនក្ដីខ្លួនមកកាត់តុលាការសាលាដំបូង តុលាការក៏បានកោះហៅសួរនាំក្រោយមកសាលាដំបូងក៏សម្រេចថារឿងក្ដីនេះខ្វះធាតុផ្សំ សាលាដំបូងក៏បានចេញដីកាសម្រេចលើកលែងការចោទប្រកាន់មកកូនក្ដីខ្លួន ក៏ប៉ុន្តែខាងធនាគារកើតទុក្ខមិនសុខចិត្ត ក៏បានប្ដឹងមកសាលាឧទ្ធរណ៍ រួចសាលាឧទ្ធរណ៍ក៏បានពិចារណាទាំងអង្គហេតុ គឺពុំមានធាតុផ្សំគ្រប់គ្រាន់ក៏សម្រេចលើកលែងកូនក្ដីខ្លួនឱ្យ

រួចផុតពីការចោទប្រកាន់និងតម្កល់ដីកាសម្រេចរបស់សាលាដំបូងនោះដដែល ក៏ប៉ុន្តែខាងធនាគារក៏កើតទុក្ខមិនសុខចិត្តទៀតបានប្តឹងសាទុក្ខមកកាន់តុលាការកំពូល ថ្ងៃនេះតុលាការកំពូលក៏បានបើកសវនាការយកមកពិចារណាទាំងអង្គហេតុនិងអង្គច្បាប់ ។

+លោកស្រី [redacted] **ស្រីអូន** ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ [redacted] **ពេជ្រតារា** ធ្វើសេចក្តីសន្និដ្ឋានថា សូមឱ្យតុលាការផ្តល់យុត្តិធម៌ដល់កូនក្តីខ្លួន និងលើកលែងការចោទប្រកាន់ ព្រមទាំងសូមតម្កល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការដដែល ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់អំណានសារណាការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនត្រូវចោទ

ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

យល់ឃើញថា បណ្តឹងសាទុក្ខលេខ **៨៤៥ ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២** ត្រូវបានដាក់ដោយលោក [redacted] **សុខោ** ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីប្រឆាំងនឹងសាលដីកាព្រហ្មទណ្ឌលេខ **៧៩ ក្រIII «ឃ» ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២២** របស់សភាស៊ើបសួរសាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចតម្កល់ដីកាលើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ [redacted] ពេជ្រតារា ដោយពុំមានលិខិតប្រគល់សិទ្ធិឱ្យមេធាវី [redacted] សុខោ ប្តឹងសាទុក្ខស្របតាមបញ្ញត្តិមាត្រា ៤២២ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌទេ។ ហេតុនេះ បណ្តឹងសាទុក្ខដូចខាងលើនេះគឺជាបណ្តឹងសាទុក្ខធ្វើឡើងខុសច្បាប់។

## ហេតុដូច្នេះ

## សម្រេច

-បដិសេធបណ្តឹងសាទុក្ខលេខ ៨៤៥ **ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០២២** របស់លោកមេធាវី [redacted] សុខោ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] ណុន | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

.................................................................................................................................

**បានឃើញ**

ថ្ងៃ.......ខែ.......ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០២៣
**ប្រធានអង្គជំនុំជម្រះ**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។
ថ្ងៃ.......ខែ.......ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]

[redacted]...ក្រឡាបញ្ជីតុលាការកំពូល បញ្ជាក់ថា សាលដីកានេះបានចូលជាស្ថាពរ នៅថ្ងៃទី.......ខែ.......ឆ្នាំ.......
រមានអានុភាពអនុវត្ត តាមច្បាប់ ។"

"សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាទ្រង់ត្រាស់បង្គាប់មកអ្នកអនុវត្តសាលដីកាឲ្យសម្រេចមសាលដីកានេះ និងឲ្យអាជ្ញាធរគ្រប់តំណែង គ្រប់ថ្នាក់ជួយអនុវត្តសាលដីកានេះ បើមានសំណូមពរត្រឹមត្រូវតាមរប់ ។"

ថ្ងៃ.......ខែ.......ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០២៣
**ក្រឡាបញ្ជី**

[redacted]